រាជរដ្ឋាភិបាលកម្ពុជា

# វេទិការវាងរាជរដ្ឋាភិបាល
# និងរដ្ឋបាលថ្នាក់ក្រោមជាតិ
# ស្តីពី
# "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
# ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"

ខែមីនា ឆ្នាំ២០២៤

# មាតិកា


១. សេចក្តីជូនដំណឹងលេខ១៧៤ សជណ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំការពិនិត្យ សម្រេចលើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"

២. ឯកសារទស្សនទានសម្រាប់ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"

៣. សេចក្តីណែនាំលេខ០១៥ សណន/គ.ជ.អ.ប. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ស្តីពីដំណើរការនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"

៤. សេចក្តីសម្រេចលេខ០១៤ សសរ/គ.ជ.អ.ប. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ស្តីពីការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងក្របខណ្ឌពេលវេលាសម្រាប់ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៤។


*****

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១៧៤ សជណ

ថ្ងៃ ចន្ទ ១១រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមជម្រាបជូន**

**ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**កម្មវត្ថុ៖** ករណីសំណើសុំការពិនិត្យ សម្រេចលើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់ការរៀបចំវេទិការវាង រាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមប្រធានបទស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"។

**យោង ៖**
- លិខិតលេខ០០៥ លស/គ.ជ.អ.ប ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ របស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)
- លិខិតលេខ០២៥ ខន/០២៤ សជណ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ខុទ្ទកាល័យសម្តេច មហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តម អភិសន្តិបណ្ឌិតមេត្តាជ្រាបថា រាជរដ្ឋាភិបាលសម្រេចឯកភាពលើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់ការរៀបចំ វេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមប្រធានបទស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០" ដូចមានភ្ជាប់មកជាមួយ។ គណៈកម្មាធិការជាតិសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ត្រូវរៀបចំសេចក្តីណែនាំបច្ចេកទេសអំពី កិច្ចដំណើរការនៃការរៀបចំវេទិកានេះ និងផ្សព្វផ្សាយអនុវត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នពាក់ព័ន្ធ ចាប់ពីឆ្នាំ២០២៤នេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិសន្តិបណ្ឌិតមេត្តាជ្រាបនិងចាត់ចែងអនុវត្ត។

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**កែន សត្ថា**

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

# ឯកសារទស្សនទានសម្រាប់ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"

### ខែមករា ឆ្នាំ២០២៤

## ១. សាវតា

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬហៅថាកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់ផ្នែកអភិបាលកិច្ច ដែលផ្ដោតលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលការណ៍រដ្ឋបាលឯកភាព និងគោលការណ៍អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យដោយមានការចូលរួមពីប្រជាពលរដ្ឋ ព្រមទាំងការបែងចែកមុខងារឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការផ្ទេរមុខងារ ធនធាន សិទ្ធិអំណាច និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការដោះស្រាយបញ្ហាប្រឈម ការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានចាប់ផ្ដើមអនុវត្តដំណាក់កាលដំបូងជាប្រវត្តិសាស្ត្រ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស និងការដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់នាឆ្នាំ២០០២ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ផ្អែកលើភាពជោគជ័យនៃការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានសម្រេចពង្រីកវិសាលភាពនៃកំណែទម្រង់នេះទៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត តាមរយៈការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (២០០៥) ការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) ព្រមទាំងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាឆ្នាំ២០០៩។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកំណែទម្រង់ដែលមានលក្ខណៈស្មុគស្មាញ ប៉ុន្តែជាកំណែទម្រង់ដែលមានផលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយសារកំណែទម្រង់នេះតម្រូវឱ្យមានការផ្ទេរ និងការបែងចែកមុខងារ និងការទទួលខុសត្រូវរវាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបតម្រូវការប្រជាពលរដ្ឋតាមមូលដ្ឋាននានា សំដៅលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលបានតម្កល់ការប្តេជ្ញាចិត្តខាងនយោបាយយ៉ាងមុតមាំ និងច្បាស់លាស់ក្នុងការអនុវត្តកំណែទម្រង់នេះឱ្យទទួលបានជោគជ័យសម្រាប់រយៈពេលវែង។ ដើម្បីធានាដល់ការអនុវត្តកំណែទម្រង់នេះឱ្យទទួលបានជោគជ័យ ច្បាប់រៀបចំអង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានតម្រូវឱ្យរាជរដ្ឋាភិបាល ដែលមាន គ.ជ.អ.ប.ជាសេនាធិការ ត្រូវរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តកំណែទម្រង់នេះជាជំហានៗ ផ្អែកលើបរិបទជាក់ស្តែងនៃស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់កម្ពុជា។

រហូតមកដល់បច្ចុប្បន្ននេះ គ.ជ.អ.ប.បានដឹកនាំ សម្របសម្រួលរៀបចំ និងអនុវត្តបញ្ចប់កម្មវិធីជាតិរយៈពេល១០ឆ្នាំ ដំណាក់កាលទី១ (២០១០-២០២០) ប្រកបដោយជោគជ័យ ព្រមទាំងបាន និងកំពុងបន្តដឹកនាំសម្របសម្រួលការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំ ដំណាក់កាលទី២ (២០២១-២០៣០)។ កម្មវិធីជាតិដំណាក់កាលនីមួយៗត្រូវបានអនុវត្ត តាមរយៈការរៀបចំឱ្យមានផែនការរយៈពេលមធ្យមតាមដំណាក់កាលនីមួយៗ ព្រមទាំងការរៀបចំឱ្យមានផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដែលមានការចូលរួមអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។

## ២. ការរៀបចំវេទិកានានា នាពេលកន្លងមក

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ត្រូវបានរៀបចំ និងអនុវត្តដោយផ្អែកលើបរិបទជាក់ស្តែងរបស់កម្ពុជាដោយប្រកាន់ខ្ជាប់នូវវិធីសាស្ត្រអនុវត្តផង រៀនសូត្រផង និងដកស្រង់បទពិសោធន៍ផង កែលម្អជាបណ្តើរៗផង ដោយមានការពិភាក្សា ពិគ្រោះយោបល់ និងការស្រុះស្រួលឯកភាពគ្នារវាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។ ក្នុងន័យនេះ នាពេលកន្លងមក គ.ជ.អ.ប. បានរៀបចំព្រឹត្តិការណ៍សំខាន់ៗជាច្រើន ដើម្បីឆ្លុះបញ្ចាំងអំពីការអនុវត្តជាក់ស្តែង ប្រមូលមេរៀន និងបទពិសោធន៍ល្អៗសម្រាប់ជាមូលដ្ឋានក្នុងការបន្តអនុវត្តកំណែទម្រង់នេះជាបន្តបន្ទាប់។ ព្រឹត្តិការណ៍សំខាន់ៗទាំងនេះ រួមមានដូចជា៖

- សមាជក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសដែលបានរៀបចំឡើងនាឆ្នាំ២០០៦ និងឆ្នាំ២០១១ ដោយមានការចូលរួមពីតំណាងរដ្ឋបាលឃុំ សង្កាត់មួយចំនួន (មេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់)

តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត សរុបចំនួនប្រមាណ ៧០០នាក់។ សមាជនេះបានផ្តោតទៅលើខ្លឹមសារសំខាន់ៗនៃការអនុវត្តច្បាប់គ្រប់គ្រងឃុំ សង្កាត់ និងកម្មវិធីកំណែទម្រង់វិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ដោយឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការកំណត់វិធានការដោះស្រាយសម្រាប់រយៈពេលខ្លី មធ្យម និងវែង។ សមាជក្រុមប្រឹក្សាឃុំ សង្កាត់នេះក៏បានការអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីបិទសមាជទាំងពីរនេះផងដែរ។

- សន្និសីទជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ “**មេរៀន បទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត**” ត្រូវបានរៀបចំឡើងរយៈពេល២ថ្ងៃ ក្នុងឆ្នាំ២០១៨ ដោយមានអ្នកចូលរួម**សរុបចំនួនប្រមាណ ២,៧០០នាក់** មកពីតំណាងព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាអ្នកច្បាប់ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរអង្គភាពពាក់ព័ន្ធ តំណាងស្ថានទូត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល អ្នកសារព័ត៌មាន និងអ្នកពាក់ព័ន្ធនានា។ សន្និសីទនេះក៏មានការធ្វើបទបង្ហាញលើប្រធានបទសំខាន់ៗ ដូចជា (១).វឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅនៃកំណែទម្រង់ (២).ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប. (៣).បទអន្តរាគមន៍របស់ក្រសួងសំខាន់ៗ សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ និងតំណាងអង្គការសង្គមស៊ីវិល។ ជាមួយគ្នានេះ វេទិកានេះក៏បានរៀបចំឱ្យមានវេទិកាសំណួរចម្លើយ អំពីការលើកកម្ពស់តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ សន្និសីទជាតិនេះក៏បានការអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីបិទសន្និសីទជាតិនេះ។
- សិក្ខាសាលាឆ្លុះបញ្ចាំងពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយដែលត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ ដើម្បីបូកសរុបលទ្ធផលនៃការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បញ្ហាប្រឈមនានា និងការកំណត់នូវដំណោះស្រាយ ព្រមទាំងកំណត់អំពីផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។
- សិក្ខាសាលាបូកសរុបលទ្ធផល១០ឆ្នាំនៃកម្មវិធីជាតិដំណាក់កាលទី១ និងការផ្សព្វផ្សាយកម្មវិធីជាតិដំណាក់កាលទី២ ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០២១ **ដោយមានអ្នកចូលរួមប្រមាណ ៧,០០០នាក់** (ការចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធZOOM) មកពីក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។ សិក្ខាសាលានេះបានការអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីបិទសិក្ខាសាលា។

- វេទិកាពិគ្រោះយោបល់ផ្សេងៗទៀត ដូចជា៖ កិច្ចប្រជុំពិគ្រោះយោបល់នានាទៅលើការរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារ ធនធាន សិទ្ធិអំណាច និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ល។

## ៣. សំណើរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងផ្អែកទៅលើការវិវឌ្ឍនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានឈានចូលដល់ដំណាក់កាលកាន់តែស៊ីជម្រៅដែលទាមទារឱ្យមានការពិភាក្សា និងការពិគ្រោះយោបល់ឱ្យមានការឯកភាពគ្នាក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល (ក្របខ័ណ្ឌអ្នករៀបចំគោលនយោបាយ និងអ្នកប្រតិបត្តិផ្ទាល់) និងដើម្បីផ្តល់ការតម្រង់ទិសច្បាស់លាស់សម្រាប់ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់រយៈពេលខាងមុខជាបន្តបន្ទាប់ ស្របទៅតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧នៃរដ្ឋសភា គ.ជ.អ.ប. សូមស្នើសុំរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពី **"កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"** ដែលមានគោលបំណង និងកិច្ចដំណើរការដូចខាងក្រោម៖

### ៣.១. គោលបំណង

ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានគោលបំណងពិគ្រោះពិភាក្សារវាងរាជរដ្ឋាភិបាលជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិរួមគ្នាវាយតម្លៃអំពីវឌ្ឍនភាព បញ្ហាប្រឈម កំណត់ដំណោះស្រាយ និងការដាក់ចេញនូវការតម្រង់ទិសផ្អែកគោលនយោបាយសម្រាប់សម្រួចការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

### ៣.២. ដំណើរការរៀបចំវេទិកា

ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើឡើង**រៀងរាល់៣ឆ្នាំម្តង**ដោយចាប់ផ្តើម**ពីឆ្នាំ២០២៤នេះតទៅ**។ ការរៀបចំវេទិកានេះត្រូវមានការចូលរួមពីតំណាងស្ថាប័ននីតិប្បញ្ញត្តិ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងប្រធានស្ថាប័ននានានៃរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានា តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងតំណាងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ស្ថាប័នមិនមែនរដ្ឋាភិបាល អ្នកពាក់ព័ន្ធនានា ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

វេទិកានេះត្រូវរៀបចំឡើងតាមយន្តការ និងជំហាន ដូចខាងក្រោម៖

- **ជំហានទី១៖** ការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត (ក្នុងអំឡុងត្រីមាសទី១ ឬទី២)

- **ជំហានទី២៖** ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប. (ក្នុងអំឡុងត្រីមាសទី២ ឬទី៣)
- **ជំហានទី៣៖** ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ក្នុងអំឡុងត្រីមាសទី៣ ឬទី៤)។

## ជំហានទី ១ ៖ ការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត

### ក. កម្មវិធី

ការរៀបចំវេទិកានេះគ្រោងធ្វើ**រយៈពេល២ថ្ងៃ**នៅរដ្ឋបាលរាជធានី ខេត្តនីមួយៗដោយមានរបៀបវារៈសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- របាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ឆ្លុះបញ្ចាំងពីសមិទ្ធផលធំៗ និងបញ្ហាប្រឈម)
- ការពិភាក្សា និងការកំណត់អំពីដំណោះស្រាយ និងវិធានការនានា ព្រមទាំងស្ថាប័នទទួលខុសត្រូវ និងក្របខ័ណ្ឌពេលវេលា
- ការកំណត់បញ្ហាដែលត្រូវស្នើសុំដំណោះស្រាយមករដ្ឋបាលថ្នាក់ជាតិ
- បញ្ហាផ្សេងៗ។

### ខ. សមាសភាពអ្នកចូលរួម

វេទិកានៅថ្នាក់រាជធានី ខេត្តនេះ ត្រូវរៀបចំឡើងក្រោមការដឹកនាំ និងសម្របសម្រួលដោយប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត និងមានសមាសភាពចូលរួម ដូចខាងក្រោម៖

- **ថ្នាក់រាជធានី ខេត្ត៖** ក្រុមប្រឹក្សារាជធានី ខេត្តទាំងអស់ គណៈអភិបាលរាជធានី ខេត្តទាំងអស់ ប្រធានការិយាល័យប្រជាពលរដ្ឋ នាយករដ្ឋបាល នាយកទីចាត់ការ/អង្គភាពទាំងអស់ អង្គភាពច្រកចេញចូលតែមួយ ប្រធានមន្ទីរ/អង្គភាពជំនាញទាំងអស់ និងមន្ត្រីពាក់ព័ន្ធមួយចំនួន ព្រមទាំងតំណាងសមាគមក្រុមប្រឹក្សារាជធានី ខេត្ត ងអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ដែលគាំទ្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងស្ថាប័នសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងទៀត
- **ថ្នាក់ក្រុង ស្រុក ខណ្ឌ៖** ប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ ការិយាល័យច្រកចេញចូលតែមួយ ប្រធានការិយាល័យប្រជាពលរដ្ឋទាំងអស់ និងមន្ត្រីពាក់ព័ន្ធមួយចំនួន ព្រមទាំងតំណាងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- **ថ្នាក់ឃុំ សង្កាត់៖** គ្រប់មេឃុំ/ចៅសង្កាត់ និងស្មៀនឃុំ/សង្កាត់។

### គ. ខ្លឹមសារ

វេទិកានៅថ្នាក់រាជធានី ខេត្តនេះនឹងផ្តោតទៅលើស្ថានភាព និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹង៖

- រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (មុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ)
- ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងរវាងថ្នាក់ក្រោមជាតិនិងថ្នាក់ក្រោមជាតិ
- ការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ
- ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្ម
- បញ្ហាផ្សេងៗទៀត។

## ឃ. ដំណើរការនៃការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត

ដំណើរការរៀបចំវេទិកានេះ ត្រូវប្រព្រឹត្តទៅដូចខាងក្រោម៖

**១.** រដ្ឋបាលរាជធានី ខេត្តត្រូវជូនដំណឹងដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាំងអស់ ដើម្បីប្រជុំបូកសរុបវឌ្ឍនភាព បញ្ហាប្រឈម និងសំណើសំណូមពរនានា (បញ្ហាប្រឈមដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មិនអាចដោះស្រាយបាន) ពាក់ព័ន្ធនឹងខ្លឹមសារដូចបានកំណត់ខាងលើនៅតាមរដ្ឋបាលនីមួយៗ រួចរៀបចំរបាយការណ៍សង្ខេបតាមទម្រង់គំរូដែលបានភ្ជាប់ជូន។

**២.** រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវប្រជុំក្រុមប្រឹក្សាសាមី ដោយមានការអញ្ជើញថ្នាក់ដឹកនាំភូមិ អង្គការដៃគូ និងតំណាងសហគមន៍ចូលរួមកិច្ចប្រជុំ ដើម្បីរៀបចំរបាយការណ៍សង្ខេបអំពីវឌ្ឍនភាព បញ្ហាប្រឈម និងសំណើសំណូមពរពាក់ព័ន្ធទៅនឹងខ្លឹមសារដែលបានកំណត់ខាងលើ រួចបញ្ជូនមករដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី។

**៣.** រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំកិច្ចប្រជុំជាមួយរដ្ឋបាលឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិភាក្សា និងស្វែងយល់ឱ្យបានស៊ីជម្រៅលើបញ្ហានីមួយៗដែលស្នើដោយរដ្ឋបាលឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ ព្រមទាំងត្រូវដោះស្រាយទៅតាមលទ្ធភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបូកសរុបបញ្ហា និងសំណើសំណូមពររបស់រដ្ឋបាលឃុំ សង្កាត់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផង ព្រមទាំងត្រូវបូកសរុបវឌ្ឍនភាព បញ្ហាប្រឈម និងសំណើសំណូមពរនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីផង តាមទម្រង់គំរូដែលបានជូនភ្ជាប់ រួចបញ្ជូនរបាយការណ៍បូកសរុបនេះមករដ្ឋបាលរាជធានី ខេត្ត។

**៣.** គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ.) នៃរដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវរៀបចំកិច្ចប្រជុំ ដើម្បីបូកសរុបវឌ្ឍនភាព បញ្ហាប្រឈម និង

សំណើសំណូមពរនានាដែលទទួលបានពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបូកសរុបវឌ្ឍនភាព បញ្ហាប្រឈម និងសំណើសំណូមពរនានារបស់រដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗផង ដើម្បីត្រៀមរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត។

**៤.** វេទិកានៅថ្នាក់រាជធានី ខេត្តត្រូវរៀបចំឡើងដោយរដ្ឋបាលរាជធានី ខេត្តនីមួយៗទៅតាមកម្មវិធី និងរបៀបវារៈដូចបានកំណត់ (ប្រធានក្រុមប្រឹក្សា និងអភិបាលត្រូវដឹកនាំ សម្របសម្រួលលើការពិភាក្សា និងដាក់ចេញនូវវិធានការដោះស្រាយបញ្ហាតាមករណីនីមួយៗ)។ ក្នុងករណីមិនអាចដោះស្រាយបាន រដ្ឋបាលរាជធានី ខេត្តត្រូវរៀបចំបញ្ជីបញ្ហាប្រឈម និងសំណើសំណូមពរដែលត្រូវយកមកដោះស្រាយនៅថ្នាក់ជាតិ។

**៥.** រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃវេទិកាថ្នាក់រាជធានី ខេត្ត ព្រមទាំងបញ្ជីបញ្ហាប្រឈម និងសំណើសំណូមពរដែលស្នើមកថ្នាក់ជាតិ ដើម្បីស្នើសុំការដោះស្រាយតាមទម្រង់គំរូភ្ជាប់មកជាមួយ រួចបញ្ជូនមកលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយបែកចែកនូវសំណើសំណូមពរជាបញ្ជីដាច់ដោយឡែកៗពីគ្នា រួមមាន៖

១). បញ្ហាប្រឈម និងសំណើសំណូមពររបស់រដ្ឋបាលថ្នាក់ឃុំ សង្កាត់

២). បញ្ហាប្រឈម និងសំណើសំណូមពររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង

៣). បញ្ហាប្រឈម និងសំណើសំណូមពររបស់រាជធានី ខេត្ត។

ក្នុងដំណាក់កាលដំបូង គ.ជ.អ.ប. អាចនឹងបង្កើតក្រុមការងារបច្ចេកទេសដែលមានសមាសភាពមកពីលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធផ្សេងទៀត ដើម្បីសម្របសម្រួលគាំទ្រដល់ការរៀបចំវេទិកានៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងនៅថ្នាក់រាជធានី ខេត្តណាមួយ ឬមួយចំនួនដើម្បីជាគំរូ និងដកស្រង់បទពិសោធន៍អំពីដំណើរការនៃការរៀបចំវេទិកានេះ។

គ.ជ.អ.ប. នឹងផ្តល់ការណែនាំជាក់លាក់បន្ថែមអំពីទម្រង់របាយការណ៍ និងកិច្ចដំណើរនៃការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត តាមរយៈការរៀបចំសេចក្តីណែនាំបច្ចេកទេសអំពីដំណើរការនៃការរៀបចំវេទិកានេះ។

**ជំហានទី ២ ៖ ការរៀបចំកិច្ចប្រជុំ គ.ជ.អ.ប.**

បន្ទាប់ពីទទួលបានរបាយកាណ៍ស្តីពីលទ្ធផលនៃវេទិកាថ្នាក់រាជធានី ខេត្ត គ.ជ.អ.ប.នឹងរៀបចំចាត់ចែងកិច្ចការនានា ដូចខាងក្រោម៖

**១.** ប្រគល់ភារកិច្ចឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប. បូកសរុបរបាយការណ៍លទ្ធផលនៃវេទិការបស់រដ្ឋបាលរាជធានី ខេត្ត និងបញ្ជីបញ្ហាប្រឈមតាមកិច្ចការនីមួយៗ។

**២.** ប្រគល់ភារកិច្ចជូនអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប. ទៅតាមតួនាទី និងការទទួលខុសត្រូវរបស់អនុគណៈកម្មាធិការនីមួយៗ ដើម្បីរៀបចំកិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់ជូន គ.ជ.អ.ប. អំពីសំណើដំណោះស្រាយលើបញ្ហាប្រឈមនីមួយៗដែលបានលើកស្នើដោយ

រដ្ឋបាលរាជធានី ខេត្ត និងអាចកំណត់បញ្ហាប្រឈមផ្សេងទៀតដែលត្រូវស្នើសុំដោះស្រាយក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប. ឬ/និងរាជរដ្ឋាភិបាល។

៣. គ.ជ.អ.ប. ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាដោយផ្អែកលើមតិយោបល់របស់អនុគណៈកម្មាធិការនីមួយៗ និងត្រូវកំណត់នូវបញ្ហាប្រឈមជាគន្លឹះនានាដែលត្រូវដាក់ស្នើជូនរាជរដ្ឋាភិបាលពិនិត្យ ពិភាក្សា និងដោះស្រាយក្នុងវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំហានទី ៣ ៖ ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកលើរបាយការណ៍របស់ គ.ជ.អ.ប. រាជរដ្ឋាភិបាលនឹងរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីវាយតម្លៃលើវឌ្ឍនភាព បញ្ហាប្រឈម កំណត់ដំណោះស្រាយ និងការផ្តល់ការណែនាំតម្រង់ទិសផ្នែកគោលនយោបាយសម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅពេលអនាគតដោយប្រមុខរាជរដ្ឋាភិបាល។

### ក. កម្មវិធី

ការរៀបចំវេទិកានេះ គ្រោងនឹងប្រព្រឹត្តទៅ**រយៈពេល១ព្រឹក ឬ១ថ្ងៃពេញ** ដោយមានរបៀបវារៈសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- មតិបើកវេទិកាដោយ**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- របាយការណ៍សង្ខេបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងដំណើរការនៃរៀបចំវេទិកានេះ (ដោយ គ.ជ.អ.ប.)
- បទអន្តរាគមន៍អំពីស្ថានភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្ត (ដោយតំណាងរដ្ឋបាលរាជធានី ខេត្ត)
- បទអន្តរាគមន៍អំពីស្ថានភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ (ដោយតំណាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ)
- បទអន្តរាគមន៍អំពីស្ថានភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ (ដោយតំណាងរដ្ឋបាលឃុំ សង្កាត់)
- បទអន្តរាគមន៍អំពីស្ថានភាព និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ (ដោយតំណាងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ)
- មតិបូកសរុប និងអនុសាសន៍ដឹកនាំគន្លឹះៗ (ដោយ**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**)។

### ខ. សមាសភាពចូលរួម

សមាសភាពចូលវេទិកានេះរួមមានចំនួនសរុប**ប្រមាណ ១,៥០០រូប** រួមមាន៖

- **ស្ថាប័ននីតិប្បញ្ញត្តិ៖** តំណាងរដ្ឋសភា និងព្រឹទ្ធសភា ចំនួន ១០រូប
- **ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់៖** តំណាងចំនួន ៥រូប

- **ថ្នាក់ជាតិ៖** ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង និងប្រធានស្ថាប័ន ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័ន សាលាភូមិន្ទរដ្ឋបាល តំណាងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សាឯកជន និងអ្នកពាក់ព័ន្ធនានា**សរុបចំនួនប្រមាណ ២០០រូប**
- **ថ្នាក់រាជធានី ខេត្ត៖** ប្រធានក្រុមប្រឹក្សា អភិបាលរាជធានី ខេត្ត នាយករដ្ឋបាលទាំងអស់ ប្រធានការិយាល័យប្រជាពលរដ្ឋមួយចំនួន ប្រធានអង្គភាពច្រកចេញចូលតែមួយចំនួន ប្រធានមន្ទីរ/អង្គភាពជំនាញសំខាន់ៗចំនួន៦ក្នុងមួយរាជធានី ខេត្ត**សរុបចំនួនប្រមាណ ៣០០រូប**
- **ថ្នាក់ក្រុង ស្រុក ខណ្ឌ៖** ប្រធានក្រុមប្រឹក្សានិងអភិបាលក្រុង ស្រុក ខណ្ឌមួយចំនួន ប្រធានគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារមួយចំនួន ប្រធានការិយាល័យប្រជាពលរដ្ឋមួយចំនួន ប្រធានការិយាល័យច្រកចេញចូលតែមួយមួយចំនួន **សរុបចំនួនប្រមាណ៥០០រូប** (ជ្រើសរើសយក៥០%នៃចំនួនរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់)
- **ថ្នាក់ឃុំ សង្កាត់៖** តំណាងមេឃុំ/ចៅសង្កាត់ **ចំនួនប្រមាណ ៥០០រូប** (ជ្រើសរើសយក៣០% នៃចំនួនរដ្ឋបាលឃុំ សង្កាត់ទាំងអស់)។

### គ. ខ្លឹមសារ

វេទិកានៅថ្នាក់ជាតិនឹងផ្តោតទៅលើស្ថានភាព និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹង៖

- រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (មុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ)
- ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងរវាងថ្នាក់ក្រោមជាតិនិងថ្នាក់ក្រោមជាតិ
- ការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ
- ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្ម
- បញ្ហាផ្សេងៗទៀត។

## ៤. ប្រភពថវិកា

រដ្ឋបាលរាជធានី ខេត្តត្រូវប្រើប្រាស់ថវិការបស់រដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ ដើម្បីរៀបចំការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត។

គ.ជ.អ.ប. ត្រូវប្រើប្រាស់ថវិការបស់ខ្លួនដើម្បីរៀបចំវេទិការវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីចាំបាច់ គ.ជ.អ.ប. អាចស្នើសុំកញ្ចប់ថវិកាដោយឡែកពីរាជរដ្ឋាភិបាល ដើម្បីចាត់ចែងរៀបចំវេទិកានេះ។

## ៥. ការគាំទ្រ ការតាមដាន ការត្រួតពិនិត្យលើការរៀបចំវេទិកានៅថ្នាក់ក្រោមជាតិ

គ.ជ.អ.ប. ត្រូវរៀបចំក្រុមការងារបច្ចេកទេស ដើម្បីគាំទ្រ តាមដាន ត្រួតពិនិត្យលើការរៀបចំវេទិកា និងការអនុវត្តដំណោះស្រាយនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមការងារបច្ចេកទេសនេះនឹងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីបង្គោលនៅរដ្ឋបាលថ្នាក់ក្រោមជាតិអំពីកិច្ចដំណើរការនៃការរៀបចំវេទិកានេះនៅថ្នាក់ក្រោមជាតិ ព្រមទាំងធ្វើរបាយការណ៍ជូន គ.ជ.អ.ប.។

## ៦. កិច្ចការសំខាន់ៗ

ដើម្បីធានាថាវេទិកានេះអាចប្រព្រឹត្តទៅបានដោយរលូន និងមានប្រសិទ្ធភាព ចាំបាច់ត្រូវរៀបចំកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

១. រៀបចំសំណើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** អំពីកិច្ចដំណើរការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

២. រៀបចំសេចក្តីណែនាំបច្ចេកទេសអំពីកិច្ចដំណើរការនៃការរៀបចំវេទិកានេះ។

៣. រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអនុវត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នពាក់ព័ន្ធអំពីការរៀបចំវេទិកានេះ។

៤. រៀបចំវេទិកានៅថ្នាក់រាជធានី ខេត្តនីមួយៗ។

៥. រៀបចំកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនីមួយៗនៃគ.ជ.អ.ប. និងកិច្ចប្រជុំរបស់ គ.ជ.អ.ប.។

៦. រៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដើម្បីសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

*****

៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប**
**ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**
លេខ៖ .....០១៤...[illegible]../គ.ជ.អ.ប

# សេចក្តីណែនាំ
# ស្តីពី
# ដំណើរការនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី “កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០”

យោងតាមសេចក្តីជូនដំណឹងលេខ១៧៤ សជណ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំការពិនិត្យ សម្រេចលើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់រៀបចំវេទិការវាងរាជរដ្ឋាភិបាលនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងដើម្បីពង្រឹងនិងជំរុញដំណើរការកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ចឱ្យកាន់តែមុតស្រួច និងប្រសិទ្ធភាព ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមធ្វើការណែនាំអំពីដំណើរការនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី **“កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០”** ដូចខាងក្រោម៖

## I. អំពីគោលបំណងនៃការរៀបចំវេទិកា

ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានគោលបំណងពិគ្រោះពិភាក្សារវាងរាជរដ្ឋាភិបាលជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរួមគ្នាវាយតម្លៃអំពីវឌ្ឍនភាព បញ្ហាប្រឈម កំណត់ដំណោះស្រាយ និងការដាក់ចេញនូវការតម្រង់ទិសផ្អែកគោលនយោបាយសម្រាប់សម្រួចការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ការរៀបចំវេទិកានេះត្រូវធ្វើឡើង**ជារៀងរាល់៣ឆ្នាំម្តង ដោយចាប់ផ្តើមអនុវត្តដំបូងពីឆ្នាំ២០២៤តទៅ** ក្រោមប្រធានបទស្តីពី **“កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០”** ដោយមានការចូលរួមពីតំណាងស្ថាប័ននីតិប្បញ្ញត្តិ ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ តំណាងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ស្ថាប័នមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

គ.ជ.អ.ប. នឹងដាក់ចេញនូវផែនការសកម្មភាពជាក់លាក់នៃកិច្ចដំណើរការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំគោលដៅអនុវត្តនីមួយៗ ព្រមទាំងសម្របសម្រួលជូនដំណឹងដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចាប់ផ្តើមរៀបចំវេទិកានេះទៅតាមជំហាននីមួយៗ និងតាមសមត្ថកិច្ចរៀងៗខ្លួន។

## II. កិច្ចដំណើរការ បែបបទ និងក្របខ័ណ្ឌពេលវេលានៃការរៀបចំវេទិកា

វេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំឡើងតាមជំហាន និងក្របខ័ណ្ឌពេលវេលានៃឆ្នាំដែលត្រូវអនុវត្ត ដូចខាងក្រោម៖

- **ជំហានទី ១** ៖ ការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត នៅអំឡុងត្រីមាសទី១ ឬទី២
- **ជំហានទី ២** ៖ ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប. នៅអំឡុងត្រីមាសទី២ ឬទី៣
- **ជំហានទី ៣** ៖ ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅអំឡុងត្រីមាសទី៣ ឬទី៤។

គ.ជ.អ.ប. ក្រសួង ស្ថាប័នពាក់ព័ន្ធ យន្តការនានានៃគ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មានតួនាទី ភារកិច្ច និងការទទួលខុសត្រូវក្នុងការចាត់ចែងរៀបចំវេទិកានេះទៅតាមជំហាននីមួយៗដូចខាងក្រោម៖

### ជំហានទី ១ ÷ ការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត

រដ្ឋបាលរាជធានី ខេត្តនីមួយៗដែលមានគណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវទទួលខុសត្រូវក្នុងការចាត់ចែងរៀបចំវេទិកានៅតាមរាជធានី ខេត្តសាមីនីមួយៗ ទៅតាមរបៀបវារៈ សមាសភាពអ្នកចូលរួម ខ្លឹមសារ និងនីតិវិធី បែបបទដូចខាងក្រោម៖

#### ក. របៀបវារៈនៃវេទិកាថ្នាក់រាជធានី ខេត្ត

វេទិកានៅថ្នាក់រាជធានី ខេត្តនេះត្រូវរៀបចំឡើងក្នុង**រយៈពេល ២ថ្ងៃ** នៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗដោយផ្តោតទៅលើរបៀបវារៈសំខាន់ៗ ដូចខាងក្រោម៖

១. របាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលនឹងឆ្លុះបញ្ចាំងពីសមិទ្ធផលធំៗ និងបញ្ហាប្រឈមនានា ដែលរាយការណ៍ដោយរដ្ឋបាលរាជធានី ខេត្ត ក្នុងរយៈពេល៣ឆ្នាំកន្លងមក

២. បទអន្តរាគមន៍នានាទៅលើប្រធានបទសំខាន់ៗពាក់ព័ន្ធទៅនឹងដំណើរការនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយ៖

- ✓ តំណាងរដ្ឋបាលឃុំ សង្កាត់
- ✓ តំណាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ✓ តំណាងមន្ទីរពាក់ព័ន្ធមួយចំនួន
- ✓ តំណាងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

- ✓ តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល
- ✓ អ្នកពាក់ព័ន្ធនានាតាមការចាំបាច់។

៣. ការពិនិត្យ ពិភាក្សា និងការដាក់ចេញវិធានការសម្រាប់ដោះស្រាយបញ្ហាប្រឈមតាមករណីនីមួយៗដែលស្នើឡើងដោយរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលរាជធានី ខេត្តទៅតាមប្រធានបទដែលបានកំណត់ក្នុងចំណុច **"គ" នៃសេចក្តីណែនាំនេះ** ព្រមទាំងកំណត់ស្ថាប័នទទួលខុសត្រូវ និងក្របខ័ណ្ឌពេលវេលាអនុវត្ត

៤. ការកំណត់បញ្ហាប្រឈមជាគន្លឹះៗដែលត្រូវស្នើសុំការធ្វើអន្តរាគមន៍ដោះស្រាយពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិ រួមទាំងសំណើសំណូមពរនានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

៥. បញ្ហាផ្សេងៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

## ខ. សមាសភាពអ្នកចូលរួមវេទិកាថ្នាក់រាជធានី ខេត្ត

វេទិកានៅថ្នាក់រាជធានី ខេត្តត្រូវដឹកនាំ និងសម្របសម្រួលដោយប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្តនីមួយៗ និងមានសមាសភាពចូលរួម ដូចខាងក្រោម៖

- **ថ្នាក់រាជធានី ខេត្ត៖** ក្រុមប្រឹក្សារាជធានី ខេត្តទាំងអស់ គណៈអភិបាលរាជធានី ខេត្តទាំងអស់ ប្រធានការិយាល័យប្រជាពលរដ្ឋ នាយករដ្ឋបាល នាយកទីចាត់ការ/អង្គភាពទាំងអស់ អង្គភាពច្រកចេញចូលតែមួយ ប្រធានមន្ទីរ/អង្គភាពជំនាញទាំងអស់ និងមន្ត្រីពាក់ព័ន្ធមួយចំនួន ព្រមទាំងតំណាងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ដែលគាំទ្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ស្ថាប័នសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធនានា។
- **ថ្នាក់ក្រុង ស្រុក ខណ្ឌ៖** ប្រធានក្រុមប្រឹក្សានិងអភិបាលក្រុង ស្រុក ខណ្ឌទាំងអស់ ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ប្រធានការិយាល័យច្រកចេញចូលតែមួយទាំងអស់ ប្រធានការិយាល័យប្រជាពលរដ្ឋទាំងអស់ និងមន្ត្រីពាក់ព័ន្ធមួយចំនួន។
- **ថ្នាក់ឃុំ សង្កាត់៖** គ្រប់មេឃុំ/ចៅសង្កាត់ និងស្មៀនឃុំ/សង្កាត់។

## គ. ខ្លឹមសារ

វេទិកានៅថ្នាក់រាជធានី ខេត្តនេះ (រួមទាំងកិច្ចប្រជុំនៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់ក្រុង ស្រុក ខណ្ឌ) ត្រូវពិនិត្យ ពិភាក្សាដោយផ្តោតទៅលើខ្លឹមសារ ឬប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងស្ថានភាព និងបញ្ហាប្រឈមនានាដូចខាងក្រោម ៖

- រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (មុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ)
- ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងរវាងថ្នាក់ក្រោមជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ
- ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្មមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ
- បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

យោងតាមរបៀបវារៈ សមាសភាព និងខ្លឹមសារខាងលើនេះ រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវកំណត់នូវកម្មវិធី ប្រធានបទ និងសមាសភាពជាក់លាក់សម្រាប់ការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត ទៅតាមស្ថានភាព និងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ។

ប្រធានក្រុមប្រឹក្សា និងអភិបាលត្រូវដឹកនាំ សម្របសម្រួលលើការពិភាក្សា និងដាក់ចេញនូវវិធានការដោះស្រាយបញ្ហាតាមករណីនីមួយៗឱ្យអស់លទ្ធភាពលើបញ្ហាប្រឈមនិងសំណើសំណូមពរនានាដែលបានលើកឡើង។ ក្នុងករណីបញ្ហាប្រឈមដែលរាជធានី ខេត្តពុំអាចសម្របសម្រួលដោះស្រាយបាន ត្រូវរៀបចំជាបញ្ជីបញ្ហាប្រឈមទាំងនោះ ដើម្បីស្នើសុំធ្វើអន្តរាគមន៍ដោះស្រាយពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិ។

### ឃ. នីតិវិធី និងបែបបទនៃការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត

ដើម្បីឈានមកដល់ការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវសម្របសម្រួល គាំទ្រ និងណែនាំដល់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យចាត់ចែងរៀបចំកិច្ចប្រជុំនៅតាមរដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌនីមួយៗ ដើម្បីបូកសរុបវឌ្ឍនភាព បញ្ហាប្រឈម និងសំណើសំណូមពរសម្រាប់ត្រៀមដាក់ជូនវេទិកានៅថ្នាក់រាជធានី ខេត្ត រួចបញ្ជូនមករដ្ឋបាលរាជធានី ខេត្តទៅតាមនីតិវិធី និងបែបបទដូចខាងក្រោម៖

#### ឃ.១. រដ្ឋបាលឃុំ សង្កាត់

មេឃុំ/ចៅសង្កាត់នីមួយៗត្រូវចាត់ចែងរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់សាមីនីមួយៗ ដើម្បីពិនិត្យ ពិភាក្សាលើខ្លឹមសារឬប្រធានបទពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ដូចដែលបានកំណត់នៅក្នុងចំណុច “គ” នៃសេចក្តីណែនាំនេះ។ ស្មៀនឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមក្នុងរយៈពេល ៣ឆ្នាំកន្លងមកតាម**ទម្រង់របាយការណ៍ក្នុងឧបសម្ព័ន្ធទី១** ដើម្បីដាក់ជូនកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ កិច្ចប្រជុំនេះត្រូវមានសមាសភាពចូលរួមពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ គណៈកម្មាធិការនានារបស់ឃុំ សង្កាត់ ថ្នាក់ដឹកនាំភូមិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងតំណាងសហគមន៍ដែលស្ថិតក្នុងមូលដ្ឋានរបស់ខ្លួន។

ក្នុងកិច្ចប្រជុំនេះ រដ្ឋបាលឃុំ សង្កាត់ត្រូវពិនិត្យ ពិភាក្សាលើបញ្ហាប្រឈមនានា និងសំណើសំណូមពរពីគ្រប់ភាគីពាក់ព័ន្ធស្របទៅតាមប្រធានបទដែលបានកំណត់ ព្រមទាំងខិតខំដាក់ចេញនូវវិធានការដោះស្រាយបញ្ហាប្រឈមនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យអស់លទ្ធភាព។ ក្នុងករណីបញ្ហាប្រឈមដែលរដ្ឋបាលឃុំ សង្កាត់ពុំអាចសម្របសម្រួលដោះស្រាយបាន ត្រូវរៀបចំជាបញ្ជីបញ្ហាប្រឈមទាំងនោះ ដើម្បីស្នើសុំធ្វើអន្តរាគមន៍ដោះស្រាយពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលរាជធានី ខេត្ត និងក្រសួង ស្ថាប័នថ្នាក់ជាតិ។

ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំខាងលើនេះ រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវរៀបចំរបាយការណ៍សង្ខេបអំពីវឌ្ឍនភាព បញ្ហាប្រឈម ដំណោះស្រាយ និងសំណើសំណូមពរ រួចបញ្ជូនមករដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗ ទៅតាម**ទម្រង់របាយការណ៍ដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី២** នៃសេចក្តីណែនាំនេះ ស្របតាមក្របខ័ណ្ឌពេលវេលាដែលបានកំណត់។

### ឃ.២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ

បន្ទាប់ពីទទួលបានរបាយការណ៍សង្ខេបពីគ្រប់រដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អភិបាលក្រុង ស្រុក ខណ្ឌនីមួយៗត្រូវចាត់ចែងរៀបចំបូកសរុបជារបាយការណ៍រួម អំពីវឌ្ឍនភាព បញ្ហាប្រឈមនានាដែលបានលើកឡើងដោយរដ្ឋបាលឃុំ សង្កាត់ **តាមទម្រង់របាយការណ៍ក្នុងឧបសម្ព័ន្ធទី៣**។ ទន្ទឹមនឹងនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗក៏ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមរបស់រដ្ឋបាលខ្លួនផងដែរ **តាមទម្រង់របាយការណ៍ក្នុងឧបសម្ព័ន្ធទី៤**។

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗត្រូវរៀបចំកិច្ចប្រជុំដែលមានប្រធានក្រុមប្រឹក្សា និងអភិបាលជាអ្នកដឹកនាំ សម្របសម្រួល ដើម្បីពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាប្រឈម ឬសំណើសំណូមពរនានាដែលបានស្នើឡើងដោយរដ្ឋបាលឃុំ សង្កាត់នីមួយៗផង និងរដ្ឋបាលក្រុង ស្រុក ខណ្ឌរបស់ខ្លួនផងទៅតាមខ្លឹមសារឬប្រធានបទដូចដែលបានកំណត់នៅក្នុង**ចំណុច “គ”** នៃសេចក្តីណែនាំនេះ។ ក្នុងករណីបញ្ហាប្រឈមដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌពុំអាចសម្របសម្រួលដោះស្រាយបាន ត្រូវរៀបចំជាបញ្ជីបញ្ហាប្រឈមទាំងនោះ ដើម្បីស្នើសុំធ្វើអន្តរាគមន៍ដោះស្រាយពីរដ្ឋបាលរាជធានី ខេត្តសាមី និងក្រសួង ស្ថាប័នថ្នាក់ជាតិ។

កិច្ចប្រជុំនេះមានសមាសភាពចូលរួមពីសមាជិកក្រុមប្រឹក្សាទាំងអស់ គណៈអភិបាល ប្រធានគណៈកម្មាធិការនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នាយកនិងនាយករងរដ្ឋបាល ប្រធានការិយាល័យប្រជាពលរដ្ឋ ប្រធានការិយាល័យ/អង្គភាពទាំងអស់ មន្ត្រីបច្ចេកទេសពាក់ព័ន្ធ មេឃុំ/ចៅសង្កាត់ ប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារថ្នាក់ឃុំ សង្កាត់ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដែលគាំទ្រការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំខាងលើនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗត្រូវរៀបចំរបាយការណ៍សង្ខេបអំពីវឌ្ឍនភាព បញ្ហាប្រឈម ដំណោះស្រាយ និងសំណើសំណូមពររបស់រដ្ឋបាលឃុំ សង្កាត់

និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួចបញ្ជូនមករដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ ទៅ**តាមទម្រង់របាយការណ៍ក្នុងឧបសម្ព័ន្ធទី៥** ស្របតាមក្របខ័ណ្ឌពេលវេលាដែលបានកំណត់។

**ឃ.៣. រដ្ឋបាលរាជធានី ខេត្ត**

បន្ទាប់ពីទទួលបានរបាយការណ៍សង្ខេបពីគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អភិបាលរាជធានី ខេត្តនីមួយៗត្រូវចាត់ចែងរៀបចំបូកសរុបជារបាយការណ៍រួម អំពីវឌ្ឍនភាព បញ្ហាប្រឈមនានាដែលបានលើកឡើងដោយរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ **តាមទម្រង់របាយការណ៍ក្នុងឧបសម្ព័ន្ធទី៦**។ ទន្ទឹមនឹងនេះ រដ្ឋបាលរាជធានី ខេត្តនីមួយៗក៏ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមរបស់រដ្ឋបាលខ្លួនផងដែរ**តាមទម្រង់របាយការណ៍ក្នុងឧបសម្ព័ន្ធទី៧**។

គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ដ.វ.វ.) នៃរដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវរៀបចំវេទិកាថ្នាក់រាជធានី ខេត្តដែលដឹកនាំ សម្របសម្រួលដោយប្រធានក្រុមប្រឹក្សា និងអភិបាលដើម្បីពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាប្រឈម ឬសំណើសំណូមពរនានាដែលបានស្នើឡើងដោយរដ្ឋបាលឃុំ សង្កាត់ផង រដ្ឋបាលក្រុង ស្រុក ខណ្ឌផង និងរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួនផងទៅតាមរបៀបវារៈ សមាសភាពអ្នកចូលរួម និងខ្លឹមសារឬប្រធានបទដែលបានកំណត់នៅក្នុង**ចំណុច "ក" "ខ" និង"គ"** ក្នុងជំហានទី ១ នៃសេចក្ដីណែនាំនេះ។ ក្នុងករណីបញ្ហាប្រឈមដែលរដ្ឋបាលរាជធានី ខេត្តពុំអាចសម្របសម្រួលដោះស្រាយបាន ត្រូវរៀបចំជាបញ្ជីបញ្ហាប្រឈមទាំងនោះ ដើម្បីស្នើសុំធ្វើអន្តរាគមន៍ដោះស្រាយពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិ។

ផ្អែកតាមលទ្ធផលនៃវេទិកានេះ រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវរៀបចំរបាយការណ៍សង្ខេបអំពីវឌ្ឍនភាព បញ្ហាប្រឈម ដំណោះស្រាយ និងសំណើសំណូមពររបស់រដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលរាជធានី ខេត្ត រួចបញ្ជូនមក គ.ជ.អ.ប. តាមរយៈលេខាធិការដ្ឋាន គ.ជ.អ.ប. **តាមទម្រង់របាយការណ៍ក្នុងឧបសម្ព័ន្ធទី៨** នៃសេចក្ដីណែនាំនេះ និងស្របតាមក្របខ័ណ្ឌពេលវេលាកំណត់។

**<u>ជំហានទី</u> ២ ÷ ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប.**

បន្ទាប់ពីទទួលបានរបាយកាណ៍ស្ដីពីលទ្ធផលនៃវេទិកាថ្នាក់រាជធានី ខេត្តៈ

១. លេខាធិការដ្ឋាន គ.ជ.អ.ប.ត្រូវបូកសរុបរបាយការណ៍លទ្ធផលនៃវេទិការបស់រដ្ឋបាលរាជធានី ខេត្តទាំងអស់សម្រាប់ដាក់ជូន គ.ជ.អ.ប.។

២. អនុគណៈកម្មការនីមួយៗនៃ គ.ជ.អ.ប. ត្រូវរៀបចំកិច្ចប្រជុំអនុគណៈកម្មការរបស់ខ្លួនដើម្បីពិនិត្យ និងផ្ដល់យោបល់ជូន គ.ជ.អ.ប. អំពីវិធានការដោះស្រាយលើបញ្ហាប្រឈម និងសំណូមពរនីមួយៗដែលបានស្នើដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រៅពីសំណើបញ្ហាប្រឈមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អនុគណៈកម្មាធិការនីមួយៗអាចកំណត់បញ្ហាប្រឈមជាគន្លឹះផ្សេងៗទៀត ដែលត្រូវស្នើសុំដោះស្រាយក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប. ឬរាជរដ្ឋាភិបាល។

៣. ផ្អែកលើមតិយោបល់របស់អនុគណៈកម្មាធិការនីមួយៗ គ.ជ.អ.ប. នឹងរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានា ព្រមទាំងត្រូវកំណត់នូវបញ្ហាប្រឈមជាគន្លឹះនានា

និងរៀបចំជារបាយការណ៍សង្ខេបដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ ពិភាក្សា និងដោះស្រាយក្នុងវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ជំហានទី ៣ ៖ ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

ផ្អែកលើរបាយការណ៍របស់ គ.ជ.អ.ប. រាជរដ្ឋាភិបាលនឹងរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីវាយតម្លៃលើវឌ្ឍនភាព បញ្ហាប្រឈម កំណត់ដំណោះស្រាយ និងផ្តល់ការណែនាំតម្រង់ទិសផ្នែកគោលនយោបាយសម្រាប់ជំរុញការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

វេទិកានេះនឹងប្រព្រឹត្តទៅតាមរបៀបវារៈ សមាសភាព និងខ្លឹមសារដូចខាងក្រោម៖

ក. របៀបវារៈ

ការរៀបចំវេទិកានេះនឹងប្រព្រឹត្តទៅរ**យៈពេល១ព្រឹក ឬ១ថ្ងៃពេញ** ដោយមានរបៀបវារៈសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

១. មតិបើកវេទិកាដោយ**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**

២. របាយការណ៍សង្ខេបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងដំណើរការនៃរៀបចំវេទិកា (ដោយ គ.ជ.អ.ប.)

៣. បទអន្តរាគមន៍អំពីស្ថានភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្ត (ដោយតំណាងរដ្ឋបាលរាជធានី ខេត្ត)

៤. បទអន្តរាគមន៍អំពីស្ថានភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ (ដោយតំណាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ)

៥. បទអន្តរាគមន៍អំពីស្ថានភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ (ដោយតំណាងរដ្ឋបាលឃុំ សង្កាត់)

៦. បទអន្តរាគមន៍អំពីស្ថានភាព និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ (ដោយតំណាងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ)

៧. មតិបូកសរុប និងអនុសាសន៍ដឹកនាំគន្លឹះៗ ដោយ**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**។

របៀបវារៈខាងលើនេះអាចកែប្រែ ឬបំពេញបន្ថែមតាមការចាំបាច់ ឬតាមការណែនាំរបស់**សម្តេចធិបតី នាយករដ្ឋមន្ត្រី**។

ខ. សមាសភាពចូលរួម

សមាសភាពចូលរួមវេទិកានេះ រួមមាន៖

- **តំណាងស្ថាប័ននីតិប្បញ្ញត្តិ** (រដ្ឋសភា និងព្រឹទ្ធសភា)
- **តំណាងឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់**
- **ថ្នាក់ជាតិ៖** ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង និងប្រធានស្ថាប័ន ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័ន សាលាភូមិន្ទរដ្ឋបាល តំណាងសម្ព័ន្ធភាពជាតិក្រុម

ប្រឹក្សាថ្នាក់មូលដ្ឋាន តំណាងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត អគ្គលេខាធិការសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនមួយចំនួន ព្រមទាំងអ្នកពាក់ព័ន្ធនានា

- **ថ្នាក់រាជធានី ខេត្ត៖** ប្រធានក្រុមប្រឹក្សានិងអភិបាលរាជធានី ខេត្ត នាយករដ្ឋបាលទាំងអស់ ប្រធានការិយាល័យប្រជាពលរដ្ឋមួយចំនួន ប្រធានអង្គភាពច្រកចេញចូលតែមួយមួយចំនួន ប្រធានមន្ទីរ/អង្គភាពជំនាញសំខាន់ៗមួយចំនួន
- **ថ្នាក់ក្រុង ស្រុក ខណ្ឌ៖** ប្រធានក្រុមប្រឹក្សានិងអភិបាលក្រុង ស្រុក ខណ្ឌមួយចំនួន ប្រធានគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារមួយចំនួន នាយករដ្ឋបាលមួយចំនួន ប្រធានការិយាល័យប្រជាពលរដ្ឋមួយចំនួន ប្រធានការិយាល័យច្រកចេញចូលតែមួយមួយចំនួន
- **ថ្នាក់ឃុំ សង្កាត់៖** មេឃុំ/ចៅសង្កាត់មួយចំនួន។

គ. ខ្លឹមសារ

វេទិកានៅថ្នាក់ជាតិនឹងផ្តោតទៅលើស្ថានភាព និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹង៖

- រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (មុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ)
- ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ
- ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្ម
- បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

យោងតាមរបៀបវារៈ សមាសភាព និងខ្លឹមសារខាងលើ គ.ជ.អ.ប. នឹងរៀបចំសេចក្តីព្រាងកម្មវិធី សមាសភាព ក្របខ័ណ្ឌពេលវេលា និងខ្លឹមសារជាក់លាក់ទៅតាមឆ្នាំនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

## III. ប្រភពធនធានសម្រាប់គាំទ្រការអនុវត្ត

រដ្ឋបាលរាជធានី ខេត្តត្រូវប្រើប្រាស់ថវិកា សម្ភារ និងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ ដើម្បីចាត់ចែងរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត ព្រមទាំងការចុះគាំទ្ររដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងកិច្ចដំណើរការរៀបចំវេទិកានេះ។

រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ត្រូវប្រើប្រាស់ថវិកា សម្ភារ និងបុគ្គលិករបស់រដ្ឋបាលសាមីនីមួយៗ ដើម្បីចាត់ចែងរៀបចំកិច្ចប្រជុំ និងកិច្ចការនានាដូចបានកំណត់ក្នុងសេចក្តីណែនាំនេះ។

គ.ជ.អ.ប. ត្រូវប្រើប្រាស់ថវិការបស់ខ្លួនដើម្បីរៀបចំវេទិការវាងរាជរដ្ឋាភិបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីចាំបាច់ គ.ជ.អ.ប. អាចស្នើសុំកញ្ចប់ថវិកាដោយឡែកពីរាជរដ្ឋាភិបាល ឬអាចកៀរគរការចូលរួមការគាំទ្រធនធានពីដៃគូអភិវឌ្ឍន៍នានាដើម្បីចាត់ចែងរៀបចំវេទិកានេះ។

## IV. កិច្ចការសំខាន់ៗ ដើម្បីគាំទ្រ តាមដាន និងត្រួតពិនិត្យលើដំណើរការនៃការរៀបចំវេទិកា

### ក. ការបង្កើតក្រុមការងារថ្នាក់ជាតិ

គ.ជ.អ.ប. នឹងបង្កើតក្រុមការងារអន្តរក្រសួង ដែលដឹកនាំសម្របសម្រួលដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ** គ.ជ.អ.ប. ដើម្បីផ្តល់ការគាំទ្រ តាមដាន ត្រួតពិនិត្យលើការរៀបចំវេទិកានេះ និងការអនុវត្តដំណោះស្រាយនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្សព្វផ្សាយ និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រុមការងារនេះត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់ គ.ជ.អ.ប.។

### ខ. ការបង្កើតក្រុមការងារថ្នាក់រាជធានី ខេត្ត

រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវបង្កើតក្រុមការងារបច្ចេកទេសជាសេនាធិការឱ្យគណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្តដើម្បីរៀបចំវេទិកាថ្នាក់រាជធានី ខេត្ត និងផ្តល់ការគាំទ្រ ណែនាំ ត្រួតពិនិត្យ និងតាមដានលើដំណើរការរៀបចំកិច្ចប្រជុំ និងកិច្ចការនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ស្របតាមសេចក្តីណែនាំនេះ។ ក្រុមការងារបច្ចេកទេសនេះមានសមាសភាព និងតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម៖

#### ខ.១. សមាសភាព៖

| | |
|---|---|
| – អភិបាលរងរាជធានី ខេត្ត ១រូប | ប្រធាន |
| – នាយករដ្ឋបាល | អនុប្រធាន |
| – នាយករងរដ្ឋបាល ១រូប | សមាជិក |
| – នាយកទីចាត់ការ/ប្រធានអង្គភាពពាក់ព័ន្ធនៃរដ្ឋបាលរាជធានី ខេត្ត | សមាជិក |
| – មន្ត្រីបច្ចេកទេសពាក់ព័ន្ធ | សមាជិក។ |

រដ្ឋបាលរាជធានី ខេត្តត្រូវកំណត់ទីចាត់ការ/អង្គភាពជាក់លាក់ណាមួយ ធ្វើជាលេខាធិការដ្ឋាននៃក្រុមការងារនេះ។

#### ខ.២. តួនាទី ភារកិច្ច៖

- ផ្សព្វផ្សាយ និងណែនាំដល់រដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អំពីកិច្ចដំណើរការនៃការរៀបចំវេទិកានេះ
- រៀបចំផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាជាក់លាក់សម្រាប់ការរៀបចំកិច្ចប្រជុំ និងវេទិកានៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមសេចក្តីណែនាំនេះ និងផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាដែលកំណត់ដោយ គ.ជ.អ.ប.

- គាំទ្រ ត្រួតពិនិត្យ និងតាមដានការរៀបចំកិច្ចប្រជុំរបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាថារដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌបានរៀបចំកិច្ចប្រជុំស្រប តាមការណែនាំ និងស្របតាមក្របខ័ណ្ឌពេលវេលាកំណត់
- ប្រមូលរបាយការណ៍បូកសរុបវឌ្ឍនភាព បញ្ហាប្រឈម និងសំណើសំណូមពីរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលរាជធានី ខេត្ត សម្រាប់រៀបចំវេទិកានៅថ្នាក់ រាជធានី ខេត្ត
- សម្របសម្រួល និងគាំទ្រដល់ដំណើរការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត
- រៀបចំរបាយការណ៍លទ្ធផលនៃវេទិកាថ្នាក់រាជធានី ខេត្តដើម្បីដាក់ជូនអភិបាលរាជធានី ខេត្ត ពិនិត្យសម្រេច និងបញ្ជូនមក គ.ជ.អ.ប.
- អនុវត្តកិច្ចការផ្សេងទៀតតាមការណែនាំរបស់អភិបាលរាជធានី ខេត្ត។

ក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើងដោយសេចក្ដីសម្រេចរបស់អភិបាលរាជធានី ខេត្ត សាមីនីមួយៗ។

ទទួលបានសេចក្ដីណែនាំនេះ គ្រប់ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប. លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រុមប្រឹក្សានិងគណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ក្រុមប្រឹក្សានិងគណៈអភិបាលខណ្ឌ និងក្រុមប្រឹក្សាឃុំនិងសង្កាត់ ត្រូវធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១១កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**អគ្គបណ្ឌិតសភាចារ្យ ស សុខា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ**សម្ដេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ**ឯកឧត្តម** ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១៖

ទម្រង់របាយការណ៍សង្ខេបអំពីវឌ្ឍនភាព បញ្ហាប្រឈម
សម្រាប់ដាក់ជូនកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

**របាយការណ៍**

**ស្តីពី**

**វឌ្ឍនភាព បញ្ហាប្រឈមក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ**
**និងវិសហមជ្ឈការរយៈពេល ៣ឆ្នាំ (២០២១-២០២៣)**

**របស់រដ្ឋបាលឃុំ/សង្កាត់..................ក្រុង/ស្រុក/ខណ្ឌ.................រាជធានី/ខេត្ត..........**

I. **វឌ្ឍនភាព**

⇨ *ផ្នែកនេះបរិយាយអំពីវឌ្ឍនភាពការងាររបស់រដ្ឋបាលឃុំ/សង្កាត់ក្នុងរយៈពេល៣ឆ្នាំកន្លងមក ដោយផ្តោតតែទៅលើសមិទ្ធផលសំខាន់ៗពាក់ព័ន្ធទៅនឹង៖*

ក). ការផ្តល់សេវាសាធារណៈ

- ការងារសន្តិសុខ សណ្តាប់ធ្នាប់ ៖
- ការផ្តល់សេវារដ្ឋបាល ៖
- ការផ្តល់សេវាសង្គម ៖
- ការចុះបញ្ជីអត្រានុកូលដ្ឋាន ៖

ខ). ការអភិវឌ្ឍមូលដ្ឋាន

- ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ៖

គ). ការធ្វើគណនេយ្យភាពចំពោះប្រជាពលរដ្ឋ

- ការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ ៖
- ការទទួល និងឆ្លើយតបមតិយោបល់ ឬបណ្តឹងតវ៉ាពីប្រជាពលរដ្ឋ ៖
- ការសម្រុះសម្រួលដោះស្រាយវិវាទមូលដ្ឋាន ៖

## II. បញ្ហាប្រឈម

⇨ *ផ្នែកនេះលើកឡើងនូវបញ្ហាប្រឈម ឬសំណើសំណូមពរនានាពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗដូចមានក្នុងតារាងខាងក្រោម ៖*

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ |
|---|---|
| 1) | រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលឃុំ សង្កាត់ |
| | |
| 2) | មុខងាររបស់រដ្ឋបាលឃុំ សង្កាត់ (មុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ) |
| | |
| 3) | ធនធានមនុស្សនៅរដ្ឋបាលឃុំ សង្កាត់ |
| | |
| 4) | ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ |
| | |
| 5) | ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងឃុំ សង្កាត់ និងរវាងឃុំ សង្កាត់និងថ្នាក់ក្រោមជាតិ ព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលឃុំ សង្កាត់ជាមួយប្រជាពលរដ្ឋ |
| | |
| 6) | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ |
| | |
